**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងរាជធានីភ្នំពេញ**

-សំណុំរឿងព្រហ្មទណ្ឌលេខ ២៩៥២
ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៩
-សំណុំរឿងស៊ើបសួរលេខ ១៩៤៦
ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៩
-សំណុំរឿងជំនុំជម្រះលេខ ២៩២៤
ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៩
-សាលក្រមលេខ: ២៤១ "ហ" ក្រ៤
ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៩

# តាងនាមប្រជារាស្ត្រខ្មែរ

សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២០ ដោយមានសមាសភាពចូលរួមដូចតទៅ:

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ប្រធានក្រុមប្រឹក្សា

**ចៅក្រមជំនុំជម្រះ**

លោកស្រី [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ
លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

<u>ដើម្បីជំនុំជម្រះលើ:</u> សំណុំរឿងព្រហ្មទណ្ឌលេខ ២៩៥២ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៩ ដែលមានជនជាប់ចោទ:

១-ឈ្មោះ [redacted] សុខណៃ ភេទប្រុស អាយុ២២ឆ្នាំ ជាតិខ្មែរ មុខរបរ មិនពិតប្រាកដ ទីកន្លែងកំណើតនៅ [redacted] ខេត្តកំពង់ចាម ទីលំនៅបច្ចុប្បន្នស្នាក់នៅ [redacted] ខេត្តកំពង់ចាម ឪពុកឈ្មោះ [redacted] អាត "រស់" ម្តាយឈ្មោះ [redacted] ភួង "រស់" នៅលើវ ជានីតិជន ទោសពីមុនគ្មាន ។ (ក្នុងឃុំ)

-ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ: ៤៥៧៣ "ញ" ដឃដ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៩ ។

២-ឈ្មោះ [redacted] សូណាល់ ហៅ សូណា ភេទប្រុស អាយុ១៩ឆ្នាំ ជាតិខ្មែរ មុខរបរ មិនពិតប្រាកដ ទីកន្លែងកំណើតនៅ [redacted] ខេត្តកំពង់ចាម ទីលំនៅបច្ចុប្បន្នស្នាក់នៅ ភូមិ [redacted] ខេត្តកំពង់ចាម ឪពុកឈ្មោះ [redacted] ឃើន "រស់" ម្តាយឈ្មោះ [redacted] ស្រ៊ាន់ "រស់" នៅលើវ ជានីតិជន ទោសពីមុនគ្មាន ។(ក្នុងឃុំ)

-ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ: ៤៥៧៥ "ញ" ដឃដ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៩ ។

៣-ឈ្មោះ [redacted]ករុណា ហៅ កាក់ ភេទប្រុស អាយុ២០ឆ្នាំ ជនជាតិខ្មែរ មុខរបរ មិនពិតប្រាកដ ទីកន្លែងកំណើតនៅ [redacted] ខេត្តកំពង់ចាម ទីលំនៅបច្ចុប្បន្នស្នាក់នៅផ្ទះជួល ផ្លូវបេតុង សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] វុទ្ធី "រស់" ម្តាយ ឈ្មោះ [redacted] សុខឿន"រស់" នៅលើវ ជានីតិជន ទោសពីមុនគ្មាន ។(ក្នុងឃុំ)

-ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ: ៤៥៧៤ "ញ" ដឃដ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៩ ។



Scanned with CamScanner

៤-ឈ្មោះ [redacted] សម្បត្តិ ហៅ ពៅ ភេទប្រុស អាយុ២៦ឆ្នាំ ជនជាតិខ្មែរ មុខរបរ មិនពិតប្រាកដ ទីកន្លែងកំណើតនៅ [redacted] រាជធានីភ្នំពេញ ទីលំនៅបច្ចុប្បន្នស្នាក់នៅផ្ទះ [redacted] រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ចំរើន "ស្លាប់" ម្ដាយឈ្មោះ [redacted] វណ្ណារ៉ា "រស់" នៅលីវ ជានីតិជន ទោសពីមុនគ្មាន ។(ក្នុងឃុំ)

-ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ: ៤៥៧២ "ញ" ដឃដ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៩ ។

ពីបទ លួចមានស្ថានទម្ងន់ទោស និងពីបទ ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិស្រែសៀម ឃុំជីរោទិ៍ទី២ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ កាលពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៩ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣, មាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៥-ឈ្មោះ [redacted] សំអូន ហៅ ប៊ូម ភេទប្រុស អាយុ២០ឆ្នាំ ជនជាតិខ្មែរ មុខរបរ មិនពិតប្រាកដ ទីកន្លែងកំណើតនៅ [redacted] ខេត្តកំពង់ចាម ទីលំនៅបច្ចុប្បន្នស្នាក់នៅ ភូមិ [redacted] ខេត្តកំពង់ចាម ឪពុកឈ្មោះ [redacted] វុទ្ធី "រស់" ម្ដាយឈ្មោះ [redacted] អ៊ីម "រស់" នៅលីវ ជានីតិជន ទោសពីមុនគ្មាន ។(ក្រៅឃុំ)

៦-ឈ្មោះ [redacted] វិចិត្រ ហៅ [redacted] ចិត្ត ភេទប្រុស អាយុ១៧ឆ្នាំ ជនជាតិខ្មែរ មុខរបរ ជាងដែក ទីកន្លែងកំណើតនៅ [redacted] ខេត្តកំពង់ចាម ទីលំនៅបច្ចុប្បន្នស្នាក់នៅ [redacted] ខេត្តកំពង់ចាម ឪពុកឈ្មោះ [redacted] ឃាត "រស់" ម្ដាយឈ្មោះ [redacted] ឃាត "រស់" នៅលីវ ជានីតិជន ទោសពីមុនគ្មាន ។(ក្រៅឃុំ)

-ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ: ៨៨០៦ "ញ" ដឃដ ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៩ ។

ជាប់ចោទពីបទ លួចមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅភូមិស្រែសៀម ឃុំជីរោទិ៍ទី២ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ កាលពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៩ តាមមាត្រា ៣៥៣, ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុជានិត ភេទប្រុស អាយុ២២ឆ្នាំ ជាតិខ្មែរ អាសយដ្ឋានបច្ចុប្បន្នភូមិពោន ឃុំមង់រៀវ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ។

## មេធាវី

-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សួណាល់ ។

-លោកស្រី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សម្បត្តិ ។

-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សុខណៃ, ឈ្មោះ [redacted] ករុណា, ឈ្មោះ [redacted] សម្បត្តិ, ឈ្មោះ [redacted] វិចិត្រ និងឈ្មោះ [redacted] សំអូន ។

## អង្គហេតុនៃរឿងដើមមានដូចតទៅ:

កាលពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៩ វេលាម៉ោង ២១ និង ៣០នាទី នៅចំណុច មុខក្លោងទ្វារវត្តចាស់ ការដ្ឋានកិនថ្មខកញ្ចាលឹមប៊ុណ្ណា ភូមិស្រែសៀម ឃុំជីរោទិ៍ទី២ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ មានករណី លួចមានស្ថានទម្ងន់ទោស (ដោយសារការប្រើអំពើហិង្សា) បានកើតឡើង ដែលបង្កដោយជនត្រូវចោទ ១-ឈ្មោះ [redacted] សុខណៃ ភេទប្រុស អាយុ២២ឆ្នាំ, ២-ឈ្មោះ [redacted] សួណាល់ ហៅ សួណា ភេទប្រុស អ យុ១៩ឆ្នាំ, ៣-ឈ្មោះ [redacted] ករុណា ហៅ កាក់ ភេទប្រុស អាយុ២០ឆ្នាំ, ៤-ឈ្មោះ [redacted] សម្បត្តិ ហៅ ពៅ ភេទប្រុស អាយុ២៦ឆ្នាំ, ៥-ឈ្មោះ [redacted] សំអូន ហៅ ប៊ូម ភេទប្រុស អាយុ



Scanned with CamScanner

២០ឆ្នាំ, និង៦-ឈ្មោះ [redacted] វិចិត្រ ភេទប្រុស អាយុ១៧ឆ្នាំ ដោយជនត្រូវចោទឈ្មោះ [redacted] ករុណា ហៅ កាក់ ជិះម៉ូតូមួយគ្រឿង ម៉ាកហុងដា សេ១២៥ ពណ៌ខ្មៅ ផលិតឆ្នាំ២០១៩ មិនចាំស្លាកលេខ ឌុបឈ្មោះ [redacted] សុខណៃ និងជនត្រូវចោទឈ្មោះ [redacted] វិចិត្រ ជិះម៉ូតូម៉ាកអ៊ិចស៊ីទ័រ ពណ៌ក្រហម គ្មានស្លាកលេខ ឌុបឈ្មោះ [redacted] សំអួន ហៅ ប៊ូម និងឈ្មោះ [redacted] សូណាល់ ហៅ សូណា ។ ពេលជនត្រូវចោទឌុបគ្នាមកដល់ចំណុចកើតហេតុខាងលើ ក៏បានឃើញជនរងគ្រោះ [redacted] សុផានិត កំពុងជិះម៉ូតូម៉ាក ស៊ុយហ្ស៊ូគីឡេត ពណ៌ខៀវលាយស ផលិតឆ្នាំ២០១៩ មានលេខតួ-លេខម៉ាស៊ីន ៤២៦៣៧៦ ពាក់ស្លាកលេខ ត្បូងឃ្មុំ 1J-6681 ភ្លាមនោះជនត្រូវចោទឈ្មោះ [redacted] សូណាល់ ហៅ សូណា ដែលអង្គុយខាងក្រោយ បានយកដាវកែច្នៃកាប់ទៅលើជនរងគ្រោះ តែមិនត្រូវ ដោយជនរងគ្រោះភ័យ ហើយបានរត់ចោលម៉ូតូ ។ បន្ទាប់មកជនត្រូវចោទឈ្មោះ [redacted] សំអួន ហៅ ប៊ូម បានចុះទៅលើកម៉ូតូរបស់ជនរងគ្រោះ ជិះឌុបឈ្មោះ [redacted] សុខណៃ គេចខ្លួន ចំណែកឈ្មោះ [redacted] វិចិត្រ ជិះម៉ូតូម៉ាកអ៊ិចស៊ីទ័រ ពណ៌ក្រហម គ្មានស្លាកលេខ ឌុបឈ្មោះ [redacted] សូណាល់ ហៅ សូណា និងជនត្រូវចោទឈ្មោះ [redacted] ករុណា ហៅ កាក់ ជិះម៉ូតូម៉ាក ហុងដា សេ១២៥ ពណ៌ខ្មៅ ផលិតឆ្នាំ២០១៩ មិនចាំស្លាកលេខជិះម្នាក់ឯងបិទគូថតាមក្រោយនាំគ្នាគេចខ្លួនបាត់អស់។ លុះដល់នៅថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៩ វេលាម៉ោងប្រហែល ១៧និង៣០ នាទី កម្លាំងជំនាញរបស់ការិយាល័យនគរបាលព្រហ្មទណ្ឌកំរិតស្រាលរាជធានីភ្នំពេញ បានស្រាវជ្រាវឈានដល់ការឃាត់ខ្លួនបានជនត្រូវចោទ ចំនួន០៣នាក់ ១-ឈ្មោះ [redacted] វណ្ណធី, ២-ឈ្មោះ [redacted] សូណាល់ ហៅ សូណា និង ៣-ឈ្មោះ [redacted] សុខណៃ នៅចំណុចមុខផ្ទះផ្លូវលេខ៧២ ផ្លូវបេតុង ភូមិទួលពង្រ សង្កាត់ចោមចៅទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ និងនៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៩ វេលាម៉ោង ១១និង៤០នាទី កម្លាំងការិយាល័យបន្តស្រាវជ្រាវជនត្រូវចោទបានម្នាក់ទៀត ឈ្មោះ [redacted] សម្បត្តិ ភេទប្រុស អាយុ២៦ឆ្នាំ នៅចំណុចក្នុងវត្តនន្ទមុនី ផ្លូវមុនីរ៉េត សង្កាត់ស្ទឹងមានជ័យ២ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ក្នុងរឿងផ្សេងមួយទៀត។ ពេលធ្វើតេស្តទឹកនោមជនត្រូវចោទទាំងបួននាក់ ឃើញមានផ្ទុកនូវសារធាតុញៀន។ បន្ទាប់មកសមត្ថកិច្ចបានកសាងសំណុំរឿងបញ្ជូនមកអយ្យការសាលាដំបូងរាជធានីភ្នំពេញ ដើម្បីចាត់ការតាមនីតិវិធីតែម្តង។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ: ៣០០១ អ.យ.ន ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៩ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ: ៣៨១១ “ញ” ដង ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] សូណាល់ បានឆ្លើយថា៖ កាលពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៩ នៅមុខ ក្លោងទ្វារវត្តចាស់គឺខ្លួនបានទៅជក់ថ្នាំញៀន។ ក្រោយពេលជក់ថ្នាំញៀនរួចខ្លួនបានជិះម៉ូតូ រួចបានជួបនឹងអ្នកជិះម៉ូតូម៉ាកឡេត ហើយក៏បានជិះម៉ូតូដេញតាម អ្នកជិះម៉ូតូម៉ាកឡេត ពណ៌ខៀវលាយស ក៏បានរត់ចោលម៉ូតូ។ ដោយឃើញឱកាសល្អខ្លួនក៏បានយកម៉ូតូនោះក្នុងគោលបំណងយកទៅលក់ ដើម្បីយកលុយមកទិញថ្នាំញៀន។ ពេលធ្វើសកម្មភាព គឺមានខ្លួន [redacted] ករុណា និង [redacted] សុខណៃ ។ ចំពោះឈ្មោះ [redacted] វិចិត្រ និងឈ្មោះ ប៊ូម គឺខ្លួនមិនស្គាល់ទេ។ ថ្ងៃកើតហេតុគឺខ្លួនបានជិះម៉ូតូទៅដោយមានគ្នា ០៣នាក់ខាងលើ ពេលទៅដល់កន្លែងវាយថ្ម ខ្លួនបានទាញដាវ ស្រាប់តែអ្នក ជិះម៉ូតូឡេតរត់ចោលម៉ូតូ ហើយឈ្មោះ [redacted] សុខណៃ ជាអ្នកទៅយកម៉ូតូម៉ាកឡេតនោះទៅលក់បានប្រាក់ចំនួន ២០០ (ពីររយ) ដុល្លារអាមេរិក ។ ខ្លួនចេះប្រើប្រាស់ថ្នាំញៀនយូរហើយ។ នៅថ្ងៃកើតហេតុនេះ ជនរងគ្រោះមិនមានរបួសទេ ហើយនៅថ្ងៃកើតហេតុនេះផងដែរ ឈ្មោះ [redacted] វិចិត្រ និងឈ្មោះ ប៊ូម មិនបានចូលរួមធ្វើសកម្មភាពជាមួយខ្លួនទេ ។ ខ្លួនធ្លាប់បានប្រព្រឹត្តបទល្មើស ០២ដងរួចមកហើយ ហើយមានគ្នាតែបីនាក់ទេ។ លើកទី១ នៅខេត្តត្បូងឃ្មុំ មុំទន្លេបិទ មុនពេលធ្វើសកម្មភាពយកម៉ូតូម៉ាកឡេតមានឈ្មោះ [redacted] សុខណៃ និងឈ្មោះ [redacted] ករុណា ។ នៅថ្ងៃកើតហេតុ ខ្លួនមិនដឹងថា ឈ្មោះ [redacted] សុខណៃ យកម៉ូតូទៅលក់ឱ្យអ្នកណាទេ ហើយថ្ងៃកើតហេតុ មិនមានឈ្មោះ [redacted] សម្បត្តិ ចូលរួមទេ។ នៅថ្ងៃកើតហេតុខ្លួនគ្រាន់តែដកដាវយកមកគម្រាមតែប៉ុណ្ណោះ។



Scanned with CamScanner

-ជនជាប់ចោទឈ្មោះ [redacted] សុខណៃ បានឆ្លើយថា៖ នៅថ្ងៃកើតហេតុ ខ្លួនពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់មែន ដោយមានគ្នាបីនាក់ គឺមានខ្លួន , [redacted] ករុណា និង [redacted] សូណាល់ ។ នៅថ្ងៃកើតហេតុ ខ្លួនមានគ្នាបីនាក់ខាងលើ បានជិះម៉ូតូឌុបគ្នាដល់កន្លែងវាយថ្ម ក៏បានឃើញជនរងគ្រោះជិះម៉ូតូលេតឌុបគ្នា ក៏បានជិះម៉ូតូទៅគៀកហើយយកដាវទៅកំឡា (ដកដាវ) មានប្រវែង ៤.៥ តឹក ដែលដាវនោះគឺបានមកត១គ្នា។ ខ្លួនជាអ្នកលើកម៉ូតូរបស់ជនរងគ្រោះ ហើយពីរនាក់ទៀតដែលជិះម៉ូតូឌុបគ្នានោះ បានមកភ្នំពេញដើម្បីយកម៉ូតូទៅលក់ឲ្យឈ្មោះ [redacted] បានលុយ ៧០០ (ប្រាំពីររយ)ដុល្លារ-អាមេរិក ចែកគ្នាបានម្នាក់ ២០០ (ពីររយ) ដុល្លារអាមេរិក សល់ ១០០(មួយរយ) ដុល្លារអាមេរិក ដោយឈ្មោះ [redacted] ជាអ្នកឲ្យលុយទិញម៉ូតូមកខ្លួន។ ខ្លួនចេះប្រើប្រាស់ថ្នាំញៀន ០១ឆ្នាំមកហើយ។ ខ្លួនមិនដែលស្គាល់ឈ្មោះ ចំរើន សម្បត្តិ ពីមុនមកទេ។ ពេលយកម៉ូតូមកលក់នៅភ្នំពេញ គឺខ្លួនបានទូរស័ព្ទទៅឈ្មោះ [redacted] មិនមែនឈ្មោះ [redacted] សម្បត្តិ ទេ។

-ជនជាប់ចោទឈ្មោះ [redacted] ករុណា បានឆ្លើយថា៖ ខ្លួនពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់មែន ដោយពេលនោះមានគ្នា បីនាក់ គឺមានខ្លួន ,សូណាល និង [redacted] សុខណៃ បានជិះទៅរួចប្រទះឃើញមនុស្សប្រុសពីរនាក់ជិះម៉ូតូម៉ាក លេតដែលមិនស្គាល់ឈ្មោះ រួចពួកខ្លួនបានជិះ ម៉ូតូវ៉ាហើយពួកនោះដេរពួកខ្លួន ហើយឈ្មោះ [redacted] សុខណៃ បានយកម៉ូតូទៅលក់ចែកគ្នាបាន ១០០ (មួយរយ) ដុល្លារអាមេរិក ហើយម៉ោងប្រហែលបីជាងភ្លឺគេឲ្យខ្លួន ១០០ ដុល្លារអាមេរិក តែខ្លួនមិនបានទៅភ្នំពេញលក់ម៉ូតូជាមួយគេទេ គឺក្រោយកើតហេតុខ្លួនត្រលប់ទៅផ្ទះវិញ។ ខ្លួនមិនដែលស្គាល់ឈ្មោះ [redacted] សម្បត្តិ ,ឈ្មោះ ប៉ូម និងឈ្មោះ [redacted] វិចិត្រ ទេ។ ប៉ូលីសចាប់ខ្លួននៅផ្ទះដួលចតុមុខភ្នំពេញ។

-ជនជាប់ចោទឈ្មោះ [redacted] សម្បត្តិ បានឆ្លើយថា៖ ថ្ងៃកើតហេតុខ្លួនកំពុងហូបអីនៅផ្ទះរបស់ខ្លួន គឺមានតែខ្លួនម្នាក់ឯង ។ នៅពេលព្រឹកម៉ោងប្រាំបីកន្លះ ខ្លួនបានទៅមើលម៉ូតូឡេត ដែលឈ្មោះ ម៉េង បានទូរស័ព្ទហៅខ្លួនទិញថាជាម៉ូតូអត់ពន្ធយកមកពីថៃ ហើយពេលខ្លួនមើលម៉ូតូទៅឃើញតែគីឡូតិច (១,០០០គីឡូ) ខ្លួនគិតថាជាម៉ូតូអត់ពន្ធមកពីថៃមែនខ្លួនក៏បានទិញ។ ខ្លួនមិនបានចូលរួមធ្វើសកម្មភាពប្លន់ទេ ហើយក៏មិនដឹងថាម៉ូតូនោះគេប្លន់មកដែរ។ ខ្លួនធ្លាប់ហូបអីជាមួយឈ្មោះ ម៉េង ហើយបានស្គាល់ឈ្មោះ ម៉េង។ ខ្លួនជាបុគ្គលិកផ្សាយផលិតផល មិនមែនមានមុខរបរជាអ្នកទិញម៉ូតូនោះទេ។ ខ្លួនមិនដែលស្គាល់ឈ្មោះ [redacted] សុណៃ ទេ ហើយក៏មិនដែលស្គាល់ឈ្មោះ ឡេង សុខណៃ, ឈ្មោះ [redacted] ករុណា និងឈ្មោះ [redacted] សូណាល់ ដែរ។ ពេលទទួលទូរស័ព្ទពីឈ្មោះ ម៉េង ម៉ោងប្រហែល១០យប់ ខ្លួនបានទៅជួបឈ្មោះ ម៉េង តែមិនជួបឈ្មោះ ម៉េង ខ្លួនក៏ទៅជួបឈ្មោះ [redacted] សុខណៃ រួចក៏ត្រលប់ទៅវិញ។ លុះស្អែកឡើងថ្ងៃទី២៨ ទើបខ្លួនបានទៅទិញម៉ូតូពីឈ្មោះ ម៉េង តម្លៃ ៨០០ (ប្រាំបីរយ) ដុល្លារអាមេរិក។ ខ្លួនមិនដែលស្គាល់ឈ្មោះ [redacted] វិចិត្រ និងឈ្មោះ ប៉ូម ទេ ។

-ជនជាប់ចោទឈ្មោះ [redacted] វិចិត្រ បានឆ្លើយថា៖ ខ្លួនរកធ្វើការនៅភ្នំពេញ តែពេលចាប់ខ្លួនគឺនៅអូររាំង។ ខ្លួនពុំធ្លាប់បានឃើញមានដីកាកោះពីតុលាការទេ។ ខ្លួនមិនដឹងថាគេចាប់ខ្លួនពីរឿងអ្វីទេ។ ខ្លួនមិនដែលស្គាល់ឈ្មោះ ប៉ូម ទេ។ មុនពេលឃាត់ខ្លួន ខ្លួនជិះម៉ូតូម៉ាក ឌូក ពណ៌ផ្កាឈូក ដែលពូរបស់ខ្លួនបានទិញទុកឲ្យជិះទៅធ្វើការ។ ខ្លួនធ្វើការនៅភ្នំពេញតាំងពីឆ្នាំ ២០១៩ ។ ខ្លួនមិនដែលស្គាល់ឈ្មោះ [redacted] សម្បត្តិ, ឈ្មោះ [redacted] ករុណា,ឈ្មោះ [redacted] សូណាល់ និងឈ្មោះ [redacted] សុខណៃ ទេ។ ខ្លួនមិនបានចូលរួមធ្វើសកម្មភាពប្លន់ជាមួយឈ្មោះ [redacted] សូណាល់,ឈ្មោះ [redacted] សុខណៃ និងឈ្មោះ [redacted] ករុណា ទេ។ ម៉ាក់ខ្លួន ទូរស័ព្ទហៅខ្លួនទៅផ្ទះ នៅថ្ងៃទី១២ ខែមេសា រហូតដល់ថ្ងៃទី០៤ ខែឧសភា ទើបខ្លួនឡើងមកភ្នំពេញវិញ។ ខ្លួនមិនបានធ្វើសកម្មភាពលួចទេ។

-តាមកំណត់ហេតុបណ្តឹងរបស់ឈ្មោះ [redacted] សុជានិត នៅនគរបាលយុត្តិធម៌បានប្តឹងថា៖ កាលពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៩ វេលាម៉ោងប្រហែល២១ និង០០នាទី ខ្លួនបានជិះម៉ូតូម៉ាក ស៊ុយហ្ស៊ុយគីឡេត ពណ៌ខៀវលាយស សេរី២០១៩ ពាក់ស្លាកលេខ ត្បូងឃ្មុំ 1J-6681 ឌុបឈ្មោះ [redacted] ពិសិដ្ឋ ភេទប្រុស អាយុ១៦ឆ្នាំ នៅភូមិឃុំជាមួយគ្នា ចេញពីភូមិជើងខាល ឃុំជីរោទិ៍ទី២ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ ស្រាប់តែពេលនោះម៉ូតូរបស់ខ្លួនអស់សាំង ហើយក៏ចូលចាក់សាំង ចំណែកឯម៉ូតូមួយគ្រឿងទៀតបានបើកទៅមុន ក្រោយពីចាក់សាំងរួចហើយខ្លួនបន្តដំណើរទៅមុខទៀត មកដល់មុខក្លោងទ្វារវត្ត

ចាស់ការដ្ឋានកិនថ្មខកញ៉ា [redacted] ប៊ុណ្ណា ស្ថិតនៅភូមិស្រែសៀម ឃុំជីរោទិ៍២ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ ស្រាប់តែខ្លួនបានឃើញម៉ូតូម៉ាក អ៊ិចសិនធ័រ ពណ៌ក្រហម០១គ្រឿង បើកចេញពីក្លោងទ្វារវត្តចាស់មក មានគ្នា០៣នាក់ ជិះមកទន្ទឹមនឹងម៉ូតូរបស់ខ្លួន ពួកវាបានច្រានម៉ូតូរបស់ខ្លួន ហើយកៀងម៉ូតូរបស់ខ្លួនចូលកៀន ម្នាក់ដែលជិះនៅកណ្ដាលបានយកដាវមកគម្រាមកាប់ខ្លួន ពេលនោះខ្លួនភ័យក៏ឈប់ម៉ូតូ រួចរត់គេចដោយមិនបានដកកូនសោរម៉ូតូទៅជាមួយ ។ បន្ទាប់មកពួកវាបានលើកយកម៉ូតូរបស់ខ្លួនជិះចេញទៅទិសខាងកើតបាត់ទៅ ។

-តាមអំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] ពិសិដ្ឋ នៅនគរបាលយុត្តិធម៌បានឆ្លើយថា៖ កាលពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៩ វេលាម៉ោងប្រហែល២១ និង ០០នាទី ពួកខ្ញុំមានគ្នា ០៥នាក់ ជិះម៉ូតូ ០២គ្រឿង ចំណែកខ្លួនជិះម៉ូតូម៉ាកស៊ុយហ្ស៊ុយគីឡេត ពណ៌ខៀវលាបស ស៊េរី២០១៩ ពាក់ស្លាកលេខ ត្បូងឃ្មុំ1J-6681 ពីក្រោយឈ្មោះ [redacted] ផានិត ភេទប្រុស អាយុ២២ឆ្នាំ នៅភូមិឃុំជាមួយខ្លួន ហើយឈ្មោះ ប៉ង់ ភេទប្រុស អាយុ២២ឆ្នាំ ដែលជាអ្នកធ្វើការជាមួយខ្លួនបានជិះម៉ូតូម៉ាកហុងដា ស៊េរី២០១៥ ជិះឌុបឈ្មោះ ផា ភេទប្រុស អាយុ១៦ឆ្នាំ នៅភូមិវៀលកណ្ដៀង ឃុំជប់ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ និងឈ្មោះ រក្ស ភេទប្រុស អាយុ២៣ឆ្នាំ នៅពេលឈ្មោះ [redacted] សុផានិត បាននាំពួកខ្លួនទៅលេងក្រុងកំពង់ចាម ពេលធ្វើដំណើរដល់ផ្លូវបំបែកទឹង ភូមិស្លាបក្លោង ឃុំជប់ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ ម៉ូតូដែលខ្ញុំជិះអស់សាំងហើយឈ្មោះ [redacted] សុផានិត បានចូលទៅចាក់សាំង ចំណែកឯ ឈ្មោះ ប៉ង់ បានជិះម៉ូតូឌុប ០២នាក់ទៀតទៅមុខបាត់ក្រោយពីចាក់សាំងរួចខ្លួន និងឈ្មោះ [redacted] សុផានិត ក៏បន្តដំណើរទៅមុខទៀត។ ពេលធ្វើដំណើរមកដល់មុខក្លោងទ្វារវត្តចាស់ ស្រាប់តែខ្លួនបានឃើញម៉ូតូម៉ាក អ៊ិចសិនធ័រ ០១ គ្រឿង ពណ៌ក្រហម ជិះគ្នា០៣នាក់ បានមកទន្ទឹមម៉ូតូដែលខ្លួនកំពុងជិះ រួចពួកវាបានច្រានម៉ូតូរបស់ខ្លួន តែមិនដួលទេ ពេលនោះ ម្នាក់ជិះម៉ូតូនៅកណ្ដាលបានយកដាវមកគម្រាមខ្លួន និងឈ្មោះ [redacted] សុផានិត ពេលនោះខ្លួន និងឈ្មោះ [redacted] សុផានិត ក៏ទុកម៉ូតូមិនបានដកកូនសោរម៉ូតូចេញ ហើយក៏នាំគ្នារត់ពួកវាក៏លើកម៉ូតូរបស់ឈ្មោះ [redacted] សុផានិត ជិះចេញទៅទិសខាងកើតបាត់ទៅ ហើយខ្លួន និងឈ្មោះ [redacted] សុផានិតបាននាំគ្នាមកប៉ុស្តិ៍ដើម្បីប្ដឹងតែម្ដង។

-តាមអំណានចម្លើយរបស់ឈ្មោះ [redacted] ករុណា នៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ឆ្លើយថា៖ ខ្លួនពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់មែន នៅថ្ងៃកើតហេតុ ក្រោយពេលផឹកស៊ីរួចពួកខ្លួនចេញប្លន់តែម្ដង ដោយឈ្មោះ ចិត្ត ជិះម៉ូតូអ៊ិចសិនធ័រឌុបអាប៊ួម និងឈ្មោះ [redacted] សួណាល់ ។ ចំណែក ឯខ្លួន ជិះម៉ូតូ ម៉ាក C១២៥ ពណ៌ខ្មៅ សេរីឆ្នាំ២០១៩ ឌុបឈ្មោះ [redacted] សុខណៃ ពេលធ្វើដំណើរទៅដល់ចំណុចផ្លូវបំបែកទឹងភូមិស្លាបក្លោង ឃុំជប់ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ ក៏ប្រទះឃើញមនុស្សប្រុសពីរនាក់មិនស្គាល់ឈ្មោះជិះម៉ូតូម៉ាកលេត ពណ៌ខៀវស ឌុបគ្នា ។ ពេលនោះ ឈ្មោះ ចិត្ត បានជិះម៉ូតូទៅកៀម៉ូតូជនរងគ្រោះឱ្យឈប់ ចំណែកខ្លួនឈប់ម៉ូតូពីក្រោយជនរងគ្រោះ ហើយឈ្មោះ [redacted] សួណាល់ បានលោតចុះពីលើម៉ូតូទាញដាវដែកកាប់ទៅលើជនរងគ្រោះ ហើយជនរងគ្រោះភ័យក៏រត់ចោលម៉ូតូបាត់ទៅ ។ រួចឈ្មោះ ប៊ួម បានយកម៉ូតូជនរងគ្រោះជិះឌុបឈ្មោះ [redacted] សុខណៃ, ឈ្មោះ ចិត្ត ជិះម៉ូតូឌុបឈ្មោះ [redacted] សួណាល់ ហើយខ្ញុំជិះម៉ូតូតែម្នាក់ឯង នាំគ្នាគេចខ្លួនមកភ្នំពេញទាំងអស់គ្នា ។ ពេលមកដល់វត្តព្រែកលាភ ឈ្មោះ [redacted] សុខណៃ បានទូរស័ព្ទ ហៅឈ្មោះ [redacted] សម្បត្តិ ភេទប្រុស អាយុប្រហែល ២៦ឆ្នាំ ឱ្យមកទិញម៉ូតូដែលប្លន់បាន ក្នុងតំលៃ ៧០០ (ប្រាំពីររយ) ដុល្លារអាមេរិក ហើយចែកគ្នាម្នាក់មួយរយដុល្លារអាមេរិក សល់លុយពីររយដុល្លារអាមេរិកផឹកស៊ីរួមគ្នា ។

-តាមអំណានចម្លើយរបស់ឈ្មោះ [redacted] សួណាល់ នៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ឆ្លើយថា៖នៅថ្ងៃកើតហេតុ ក្រោយពីផឹកស៊ីរួច ពួកខ្លួនមានគ្នាប្រាំនាក់ គឺខ្លួន, ឈ្មោះ ចិត្រ, ឈ្មោះ ប៊ួម, ឈ្មោះ [redacted] ករុណា និងឈ្មោះ [redacted] សុខណៃ ក៏ចេញប្លន់ម៉ូតូតែម្ដង ដោយឈ្មោះ ចិត្រ ជិះម៉ូតូឌុបឈ្មោះ អាប៊ួម ហើយខ្លួនអង្គុយពីក្រោយ ។ ចំណែកឯឈ្មោះ [redacted] ករុណា ជិះម៉ូតូសេ១២៥ ពណ៌ខ្មៅ សេរីឆ្នាំ២០១៩ ឌុបឈ្មោះ [redacted] សុខណៃ ។ លុះដល់ម៉ោង២១ និង០០ នាទី ពួកខ្លួនធ្វើដំណើរដល់ចំណុចភូមិស្លាបក្លោង ឃុំជប់ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ ក៏ឃើញមនុស្សពីរនាក់ អាយុ

ប្រហែល២២ឆ្នាំ ជិះម៉ូតូម៉ាក ស៊ុយស៊ុយគីលេត ពណ៌ខៀវ លាយស ហើយឈ្មោះ ចិត្រ ជិះម៉ូតូទៅកៀរម៉ូតូជនរងគ្រោះ ឱ្យឈប់ ចំណែកឯ ឈ្មោះ [redacted] ករុណា ជិះម៉ូតូឌុបឈ្មោះ [redacted] សុខណៃ ឈប់ពីក្រោយម៉ូតូជនរងគ្រោះ ។ បន្ទាប់មក ខ្លួន បានចុះពីលើម៉ូតូដកដាវផែកកាប់ទៅលើជនរងគ្រោះ ពេលនោះជនរងគ្រោះភ័យបានរត់ចោលម៉ូតូ ។ ចំណែក អាប៊ូមក៏ យកម៉ូតូជនរងគ្រោះឌុបឈ្មោះ [redacted] សុខណៃ, អាចិត្រ ជិះម៉ូតូអ៊ិចស៊ិនធ័រ ពណ៌ក្រហមឌុបខ្លួន ហើយនាំគ្នាគេចខ្លួនមក ភ្នំពេញ ម្តុំវត្តព្រែកលាភ ឈ្មោះ [redacted] សុខណៃ បានទូរស័ព្ទហៅឈ្មោះ [redacted] សម្បត្តិ ឱ្យមកទិញម៉ូតូដែលប្លន់បាន ក្នុងតំលៃ ៧០០ (ប្រាំពីររយ) ដុល្លារអាមេរិក លក់បានចែកគ្នាម្នាក់មួយរយដុល្លារអាមេរិក ចំណែកលុយសល់ផឹកស៊ីរួមគ្នា ។

-តាមអំណានចម្លើយរបស់ឈ្មោះ [redacted] សុខណៃ នៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ឆ្លើយថា៖ថ្ងៃកើតហេតុ បក្សពួកខ្លួនមានគ្នាប្រាំនាក់ គឺខ្លួន, ឈ្មោះ ចិត្ត,ឈ្មោះ ប៊ូម, ឈ្មោះ [redacted] ករុណា និងឈ្មោះ [redacted] សូណាល់ ក្រោយពីផឹកស៊ី រួច ក៏នាំគ្នាចេញប្លន់តែម្តង ដោយឈ្មោះ [redacted] ករុណា ជាអ្នកឌុបខ្លួន ជិះម៉ូតូសេ១២៥ សេរីឆ្នាំ២០១៨ ពណ៌ខ្មៅ ។ លុះដល់ ធ្វើដំណើរដល់ចំណុចផ្លូវលំទទឹង ភូមិស្លាបក្អែង ឃុំជប់ ស្រុកត្បូងឃ្មុំ ក៏ឃើញមានមនុស្សប្រុសពីរនាក់អាយុប្រហែលពីរ នាក់ អាយុប្រហែល២២ឆ្នាំ ជិះម៉ូតូស៊ុយស៊ុយគីលេត ពណ៌ខៀវស ឌុបគ្នា ឈ្មោះ ចិត្រ បានជិះម៉ូតូអ៊ិចស៊ិនធ័រ ពណ៌ ក្រហមទៅកៀរ ម៉ូតូជនរងគ្រោះឱ្យឈប់ ។ ចំណែក ម៉ូតូខ្លួនពីរនាក់ឈប់ពីក្រោយជនរងគ្រោះ ។ បន្ទាប់មកឈ្មោះ [redacted] សូណាល់ បានលោតចុះពីលើម៉ូតូទាញដាវផែកកាប់លើជនរងគ្រោះ តែជនរងគ្រោះភ័យបានរត់ចោលម៉ូតូ រួចមកអាប៊ូម បានមកយកម៉ូតូជនរងគ្រោះជិះឌុបរូបខ្លួន ឯឈ្មោះ ចិត្រ ជិះម៉ូតូអ៊ិចស៊ិនធ័រឌុបខ្លួនឈ្មោះ [redacted] សូណាល់ ហើយឈ្មោះ [redacted] ករុណា ជិះម៉ូតូម្នាក់ឯង ។ រួចពួកខ្លួនជិះម៉ូតូគេចខ្លួនទាំងអស់គ្នា មកភ្នំពេញ ពេលមកដល់ម្តុំវត្តព្រែកលាភ ខ្លួន(ឡេង សុខណៃ) បានទូរស័ព្ទហៅឈ្មោះ [redacted] សម្បត្តិ ភេទប្រុស ឱ្យមកទិញម៉ូតូដែលប្លន់បាន ក្នុងតំលៃ ៧០០ (ប្រាំពីររយ) ដុល្លារអាមេរិក ហើយលក់បានចែកលុយគ្នាបានម្នាក់មួយរយដុល្លារអាមេរិក ហើយលុយសល់ ពីររយដុល្លារអាមេរិក ផឹកស៊ីរួមគ្នាអស់ទៅ ។

-តាមអំណានចម្លើយរបស់ឈ្មោះ [redacted] សម្បត្តិ នៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ឆ្លើយថា៖ខ្លួនពិតជាបាន ទិញម៉ូតូមួយគ្រឿងម៉ាកស៊ុយស៊ុយគីលេត ពណ៌ខៀវស គ្មានស្លាកលេខ ទិញពីឈ្មោះ [redacted] សុខណៃ ភេទប្រុស ដោយវា បានប្រាប់ខ្លួនថាម៉ូតូនេះវាស៊ីពីគេ នៅម្តុំវត្តឃ្លាង ខេត្តត្បូងឃ្មុំ ក្នុងតំលៃ៧០០(ប្រាំពីររយ) ដុល្លារអាមេរិក ដោយពុំបានធ្វើ លិខិតទិញលក់ឡើយ ហើយការទិញនេះ ពួកខ្លួនណាត់ជួបគ្នា នៅមុខវត្តព្រែកលាភ សង្កាត់ព្រែកលាភ ខណ្ឌជ្រោយចង្វារ ។

-ក្រោយពីបានស្តាប់កំណត់ហេតុបណ្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ។

-ក្រោយពីបានពិនិត្យភស្តុតាង និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ ។

## សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទទាំងប្រាំនាក់រួចមក គឺគ្រាន់តែចម្លើយឆ្លើយដោះសារគេចវេសពី ការទទួលខុសត្រូវនូវអំពើរបស់ខ្លួនតែប៉ុណ្ណោះ ។ ឃើញថា ជនជាប់ចោទទាំងបី គឺឈ្មោះ [redacted] សូណាល់, ឈ្មោះ [redacted] សុខណៃ និងឈ្មោះ [redacted] ករុណា បានទទួលស្គាល់នូវអំពើដែលខ្លួនបានប្រព្រឹត្ត ក៏ប៉ុន្តែជនជាប់ចោទទាំងបីនាក់បានឆ្លើយ បដិសេធមិនស្គាល់ឈ្មោះ ចិត្ត, ឈ្មោះ ប៊ូម និងឈ្មោះ [redacted] សម្បត្តិ ប៉ុន្តែឃើញថាចម្លើយរបស់ជនជាប់ចោទទាំងបីនាក់ បានឆ្លើយនៅចៅក្រមស៊ើបនេះ គឺបានរៀបរាប់យ៉ាងលំអិតដែលអាចជឿបានថាជនជាប់ចោទទាំងបីនាក់គឺពិតជាមាន ទំនាក់ទំនងជាមួយឈ្មោះ [redacted] វិចិត្រ, ឈ្មោះ [redacted] សំអូន ហៅប៊ូម ពិតប្រាកដមែន ។ នៅក្នុងអង្គសវនាការនេះ

ឃើញពាក់ព័ន្ធនិងរឿងឈ្មោះ [redacted] សម្បត្តិ ដោយសារពុំមានភស្តុតាងដែលបញ្ជាក់ថាជនជាប់ចោទបានធ្វើសកម្មភាពលួចមានស្ថានទម្ងន់ទោសនោះទេ ក៏ប៉ុន្តែឃើញថាសកម្មភាពរបស់ជនជាប់ចោទឈ្មោះ [redacted] សម្បត្តិ នេះបានបង្ហាញឱ្យឃើញនូវសកម្មភាពដែលជាសកម្មភាពទទួលផលចោរកម្មពីជនជាប់ចោទឈ្មោះ [redacted] សួណាល់, ឈ្មោះ [redacted] ករុណា, ឈ្មោះ [redacted] សុណៃ, ឈ្មោះ [redacted] សំអួន និងឈ្មោះ [redacted] វិចិត្រ ។ ឃើញថា សកម្មភាពរបស់ជនជាប់ចោទនេះបានស្តែងឱ្យឃើញចេតនា ក៏ដូចជាបានដឹងពីសកម្មភាពដែលខ្លួនបានប្រព្រឹត្ត គឺការទិញនូវម៉ូតូដែលបានមកពីសកម្មភាពលួចរបស់ជនជាប់ចោទទាំងប្រាំនាក់ខាងលើ ។ ហេតុដូច្នេះ ដោយសារមានភស្តុតាងដាក់បន្ទុកទៅលើជនជាប់ចោទ ហើយជន-ជាប់ចោទក៏បានឆ្លើយសារភាពពីទោសកំហុសរបស់ខ្លួន ហើយមានកាលៈទេសៈស៊ីសង្វាក់ដែលអាចឱ្យតំណាងអយ្យការជឿបានថា នៅថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៩ គឺជនជាប់ចោទឈ្មោះ [redacted] សួណាល់, ឈ្មោះ [redacted] ករុណា, ឈ្មោះ [redacted] សុណៃ, ឈ្មោះ [redacted] សំអួន និងឈ្មោះ [redacted] វិចិត្រ ពិតជាបានប្រព្រឹត្តបទល្មើសលួចមានស្ថានទម្ងន់ទោសពិតប្រាកដមែន ហើយនៅពេលដែលសមត្ថកិច្ចធ្វើការឃាត់ខ្លួនជនជាប់ចោទឈ្មោះ [redacted] សុខណៃ, ឈ្មោះ [redacted] សួណាល់ និងឈ្មោះ [redacted] ករុណា នឹងបានធ្វើតេស្តទឹកនោម ហើយជនជាប់ចោទក៏បានឆ្លើយសារភាពថាខ្លួនពិតជាធ្លាប់បានប្រើប្រាស់គ្រឿងញៀនពិតប្រាកដមែន ។ ដោយឡែក ជនជាប់ចោទឈ្មោះ [redacted] សម្បត្តិ ពុំមានភស្តុងដាក់បន្ទុកទៅលើបទល្មើសលួចមានស្ថានទម្ងន់ទោសនោះទេ ក៏ប៉ុន្តែមានភស្តុតាងដាក់បន្ទុកទៅលើបទល្មើសទទួលផលចោរកម្ម ។ ហេតុដូច្នេះ តំណាងអយ្យការសុំធ្វើការសន្និដ្ឋានដោយស្នើសុំកែប្រែបទចោទលើជនជាប់ចោទឈ្មោះ [redacted] សម្បត្តិ ពីបទ លួចមានស្ថានទម្ងន់ទោស ទៅជាបទ ទទួលផលចោរកម្ម បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា៣៩៩, មាត្រា ៤០០ នៃក្រមព្រហ្មទណ្ឌ និងរក្សាបទចោទពីបទ ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ។ ២ រក្សាបទចោទលើជនជាប់ចោទឈ្មោះ [redacted] សុខណៃ, ឈ្មោះ [redacted] សួណាល់, ឈ្មោះ [redacted] ករុណា ពីបទ លួចមានស្ថានទម្ងន់ទោស និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន រក្សាបទចោទលើជនជាប់ចោទឈ្មោះ [redacted] សំអួន ហៅ បួម, ឈ្មោះ [redacted] វិចិត្រ ពីបទ លួចមានស្ថានទម្ងន់ទោស បទល្មើសដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ទុកនៅងដែលស្នើសុំឱ្យក្រុមប្រឹក្សាធ្វើការវិនិច្ឆ័យ និងសម្រេចផ្តន្ទាទោសលើជនជាប់ចោទទាំងប្រាំមួយនាក់នេះតាមនីតិវិធីច្បាប់ ។

## សេចក្តីសន្និដ្ឋានរបស់មេធាវី

-លោកស្រី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សម្បត្តិ សន្និដ្ឋានថា: ឆ្លងតាមការសួរដេញដោលក្នុងអង្គសវនាការ ក៏ដូចជាសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ គឺពិនិត្យឃើញថា កូនក្តីខ្លួនពុំមានការជាប់ពាក់ព័ន្ធជាមួយបទល្មើសលួចមានស្ថានទម្ងន់ទោស និងការប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀននោះទេ ដោយហេតុថាចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សុខណៃ, ឈ្មោះ [redacted] សួណាល់, ឈ្មោះ [redacted] ករុណា និងឈ្មោះ [redacted] វិចិត្រ នៅក្នុងអង្គហេតុថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៩ គឺកូនក្តីខ្លួនមិនបានចូលរួមធ្វើសកម្មភាពប្លន់ និងប្រព្រឹត្តអំពើហិង្សាទៅលើជនរងគ្រោះឈ្មោះ [redacted] សុជានិត នោះទេ ។ ឆ្លងតាមការបំភ្លឺរបស់កូនក្តីខ្លួនក្នុងអង្គសវនាការផងដែរ គឺពុំមានជាប់ពាក់ព័ន្ធនោះទេ ប៉ុន្តែមានករណីមួយថា កូនក្តីខ្លួនទិញម៉ូតូតែមិនបានទិញផ្ទាល់ពីឈ្មោះ [redacted] សុខណៃ ទេ គឺទិញពីឈ្មោះ ម៉េង គឺទិញនៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៩ មិនមែនទិញនៅថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៩ទេ ។ ខ្លួនសុំឱ្យកូនក្តីខ្លួនរួចផុតពីបទចោទទាក់ទងនឹងបទល្មើស លួចមានស្ថានទម្ងន់ទោស តាមមាត្រា ២៤ នៃក្រមព្រហ្មទណ្ឌ (គោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ) ។

-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សួណាល់ សន្និដ្ឋានថា:ខ្លួនសូមបញ្ជាក់ចំពោះអង្គហេតុដែលបានចោទប្រកាន់លើកូនក្តីខ្លួន គឺនៅក្នុងអង្គហេតុថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៩ កូនក្តីខ្លួនពិតជាបានឆ្លើយបញ្ជាក់ជូនតុលាការរួចមកហើយ គាត់បានធ្វើសកម្មភាពតែបីនាក់ តែអំពើសកម្មភាពដែលធ្វើនោះ ដោយសារតែគ្រឿងញៀនបានធ្វើកូនក្តីខ្លួនបាត់ស្មារតី គ្មានសតិ ធ្វើឱ្យឆាប់ខឹងក្រេវក្រោធ ហើយបានជិះម៉ូតូតាមជនរងគ្រោះ ធ្វើឱ្យ



Scanned with CamScanner

ជនរងគ្រោះភ័យរត់ចោលម៉ូតូ ហើយឈ្មោះ [redacted] សូណាល់ បានបញ្ជាក់ដែរថា ក្នុងពេលនោះពួកគាត់នៅចាំបន្តិចដែរ តែមិនឃើញម្ចាស់ម៉ូតូមកវិញ ទើបពួកគាត់បានលើកម៉ូតូជិះមកតែម្តងរហូតមកដល់ភ្នំពេញបានលក់បាត់ទៅ ។ តាមចម្លើយរបស់សហភាគាបានលើកឡើង គឺជនរងគ្រោះឆ្លើយយ៉ាងច្បាស់ថាអ្នកធ្វើសកម្មភាពមានបីនាក់ពិតប្រាកដមែន ដូចនេះគាត់ពិតជាបានសំដែងការស្មោះត្រង់ ពុំមានការភូតកុហកតុលាការ ឬមួយក៏ធ្វើឱ្យតុលាការពិបាកនិងស្វែងរកការពិតជូនពួកគាត់ និងជនរងគ្រោះនោះទេ ហើយនៅក្នុងអង្គហេតុនេះដែរ គាត់បានថាគាត់មិនបានប្រើហិង្សាទៅលើជនរងគ្រោះដើម្បីយកម៉ូតូនោះទេ ឯជនរងគ្រោះក៏បានឆ្លើយតាំងពីដំបូង ក៏ដូចជាក្នុងពាក្យបណ្តឹងដែរថា ជនរងគ្រោះនៅពេលដែលបានឃើញជនជាប់ចោទទាំងបីនាក់ភ្លាមក៏ភ័យហើយផ្តួលម៉ូតូចោល ហើយរត់យករួចខ្លួន ។ ដូចនេះ ខ្លួនសំណូមពរឱ្យលោកតុលាការប្តូបទចោទពីបទ លួចមានស្ថានទម្ងន់ទោស មកបទ លួច តាមមាត្រា ៣០០ នៃក្រមព្រហ្មទណ្ឌ និងសុំតុលាការផ្តល់ស្ថានសម្រាលឱ្យកូនក្តីខ្លួន ដោយក្តីអនុគ្រោះ ។

-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សុខណៃ, ឈ្មោះ [redacted] ករុណា, ឈ្មោះ [redacted] សម្បត្តិ, ឈ្មោះ [redacted] វិចិត្រ និងឈ្មោះ [redacted] សំអូន សន្និដ្ឋានថា: នៅក្នុងអង្គហេតុនេះឈ្មោះ [redacted] ករុណា និងឈ្មោះ [redacted] សុខណៃ បានឆ្លើយសារភាពថាខ្លួនពិតជាបានប្រព្រឹត្តដូចការចោ ប្រកាន់មែន តែមិនបានប្រើអំពើហិង្សាវាយដំ ឬកាប់ទៅលើជនរងគ្រោះទេ គ្រាន់តែខ្លួនដកដាៈមក ហើយជនរងគ្រោះបានផ្តួលម៉ូតូចោលរួចរត់ ដោយពុំបានដកសោម៉ូតូទៅទេ គឺសោនៅជាប់ម៉ូតូ ។ ដូចនេះ រាល់អំពើដែលខ្លួនធ្វើពុំមានស្ថានទម្ងន់ ឬមានអ្វីដែលធ្វើឱ្យជនរងគ្រោះរងរបួស ឬស្លាប់ នោះទេ ។ ដូចនេះ សុំឱ្យលោកប្រធានក្រុមប្រឹក្សាកែប្រែបទចោទពីមាត្រា ៣៥៧ មក មាត្រា ៣៥៦ វិញ ។ ចំណែកឯង ឈ្មោះ [redacted] សំអូន និងឈ្មោះ [redacted] វិចិត្រ សុំលោកប្រធានក្រុមប្រឹក្សាមេត្តាពិចារណាថានៅក្នុងអង្គហេតុនេះ គឺកូនក្តីខ្លួនបានបញ្ជាក់ហើយថា បានធ្វើសកម្មភាពតែបីនាក់ទេ ហើយពីរនាក់ទៀតពុំបានចូលរួមធ្វើសកម្មភាពនេះទេ ដែលមានភាពស៊ីសង្វាក់គ្នាជាមួយចម្លើយរបស់ជនរងគ្រោះ និងចម្លើយរបស់សាក្សី ។ ដូចនេះ ស្នើសុំលោកតុលាការលើកលែងចោទប្រកាន់លើកូនក្តីខ្លួនឈ្មោះ [redacted] សំអូន និងឈ្មោះ [redacted] វិចិត្រ រួចផុតពីការចោទប្រកាន់ ដោយក្តីអនុគ្រោះ ។

## សម្តីចុងក្រោយរបស់ជនជាប់ចោទ

-ជនជាប់ចោទឈ្មោះ [redacted] សុខណៃ បាននិយាយសម្តីចុងក្រោយថា៖ សំណូមពរសុំឱ្យតុលាការបន្ធូបន្ថយទោសឱ្យខ្លួនផង ។

-ជនជាប់ចោទឈ្មោះ [redacted] សូណាល់ បាននិយាយសម្តីចុងក្រោយថា៖ សំណូមពរសុំឱ្យតុលាការបន្ធូបន្ថយទោសឱ្យខ្លួនផង ។

-ជនជាប់ចោទឈ្មោះ [redacted] ករុណា បាននិយាយសម្តីចុងក្រោយថា៖ សំណូមពរសុំឱ្យតុលាការបន្ធូបន្ថយទោសឱ្យខ្លួនផង ។

-ជនជាប់ចោទឈ្មោះ [redacted] សម្បត្តិ បាននិយាយសម្តីចុងក្រោយថា៖ សំណូមពរសុំឱ្យតុលាការលើកលែងទោសឱ្យខ្លួនផង ។

-ជនជាប់ចោទឈ្មោះ [redacted] វិចិត្រ បាននិយាយសម្តី រុងក្រោយថា៖ សំណូមពរសុំឱ្យតុលាការបន្ធូបន្ថយទោសឱ្យខ្លួនផង ។

## យល់ឃើញថា

១-កាលពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៩ វេលាម៉ោង ២១ និង ៣០នាទី ជនជាប់ចោទឈ្មោះ [redacted] ករុណា ហៅ កាក់ ជិះម៉ូតូមួយគ្រឿង ម៉ាកហុងដា សេ១២៥ ពណ៌ខ្មៅ ផលិតឆ្នាំ២០១៩ មិនចាំស្លាកលេខ ឌុបឈ្មោះ [redacted] សុខណៃ និងជន-ជាប់ចោទឈ្មោះ [redacted] វិចិត្រ ជិះម៉ូតូម៉ាកអ៊ិចស៊ីទ័រ ពណ៌ក្រហម គ្មានស្លាកលេខ ឌុបឈ្មោះ [redacted] សំអូន ហៅ ប៉ឹម និងឈ្មោះ [redacted] សូណាល់ ហៅ សូណា ។ ពេលជនត្រូវចោទឌុបគ្នាមកដល់ចំណុចមុខក្លោងទ្វារវត្តចាស់ការដ្ឋានកិនថ្មខកញ្ជាលើម

ប៊ុណ្ណា ភូមិស្រែសៀម ឃុំជីរោទិ៍ទី២ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ ក៏បានឃើញជនរងគ្រោះឈ្មោះ [redacted] សុផានិត កំពុងជិះម៉ូតូម៉ាក ស៊ុយហ្ស៊ុយគីឡិត ពណ៌ខៀវលាយស ពាក់ស្លាកលេខ ត្បូងឃ្មុំ 1J-6681 ភ្លាមនោះជនត្រូវចោទឈ្មោះ [redacted] សូ-ណាល់ បានទាញដាវកាប់ទៅលើជនរងគ្រោះ តែមិនត្រូវ ហើយជនរងគ្រោះក៏បានរត់ចោលម៉ូតូបាត់។ បន្ទាប់មកឈ្មោះ [redacted] សំអូន ហៅ ប៉ូម បានចុះទៅលើកម៉ូតូរបស់ជនរងគ្រោះ ហើយបានឌុបឈ្មោះ [redacted] សុខណៃ រត់គេចខ្លួនបាត់។ លុះដល់ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៩ វេលាម៉ោង១៧ និង ៣០នាទី កម្លាំងសមត្ថកិច្ចធ្វើការស្រាវជ្រាវក៏បានឃាត់ខ្លួនជនសង្ស័យចំនួន ០៣រូប ឈ្មោះ [redacted] វណ្ណឌី ,ឈ្មោះ [redacted] សូណាល់ និងឈ្មោះ [redacted] សុខណៃ ហើយនៅថ្ងៃទី ១៨ ខែឧសភា ឆ្នាំ២០១៩ កម្លាំងសមត្ថកិច្ចក៏បន្តឃាត់ខ្លួនបានជនសង្ស័យម្នាក់ទៀតឈ្មោះ [redacted] សម្បត្តិ។ ពេលធ្វើតេស្តទឹកនោមជនត្រូវចោទទាំងបួននាក់ ឃើញមានផ្ទុកនូវសារធាតុញៀន។

២-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សូណាល់ ឈ្មោះ [redacted] សុខណៃ និងឈ្មោះ [redacted] ករុណា បានឆ្លើយប្រហាក់ប្រហែលគ្នាថា៖ខ្លួនពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់មែន ដោយថ្ងៃកើតហេតុឈ្មោះ [redacted] សូណាល់ , ឈ្មោះ [redacted] ករុណា និងឈ្មោះ [redacted] សុខណៃ បានជិះម៉ូតូរួចប្រទះឃើញជនរងគ្រោះ ជិះម៉ូតូម៉ាកឡិតពីរនាក់ រួចពួកខ្លួនក៏ជិះវ៉ា ។ ឈ្មោះ [redacted] សុខណៃ ជាអ្នកយកម៉ូតូទៅលក់នៅឯភ្នំពេញ ហើយគេចែកឱ្យខ្លួនបានប្រាក់ ១០០ (មួយរយ) ដុល្លារអាមេរិក ។ តែចំពោះការឆ្លើយថា ឈ្មោះ [redacted] វិចិត្រ និងឈ្មោះ ប៉ូម [redacted] សំអូន) ពុំចូលរួម គឺជាការឆ្លើយជួយដោះបន្ទុកគ្នា គ្មានមូលដ្ឋានត្រឹមត្រូវឡើយ ព្រោះចម្លើយរបស់ឈ្មោះ [redacted] ករុណា, ឈ្មោះ [redacted] សូណាល់ និងឈ្មោះ [redacted] សុខណៃ នៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ បានបញ្ជាក់យ៉ាងច្បាស់ថា ឈ្មោះ [redacted] វិចិត្រ និងឈ្មោះ ប៉ូម [redacted] សំ-អូន) ពិតជាបានចូលរួមធ្វើសកម្មភាព ដោយឈ្មោះ [redacted] វិចិត្រ ជិះម៉ូតូអ៊ិចសិនផ័រឌុបឈ្មោះ ប៉ូម [redacted] សំអូន) និងឈ្មោះ [redacted] សូណាល់ ពិតមែន ។

៣-តាមចម្លើយរបស់ជនជាប់ចោទទាំងអស់ និងភស្តុតាងដែលប្រមូលបាន ពុំមានភស្តុតាងណាមួយច្បាស់លាស់ថាឈ្មោះ [redacted] សម្បត្តិ ចូលរួមប្រព្រឹត្តបទល្មើស លួចមានស្ថានទម្ងន់ទោស នោះទេ តែចម្លើយរបស់ឈ្មោះ [redacted] សម្បត្តិ ខ្លួនឯង នៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ឆ្លើយថា៖ នៅថ្ងៃមិនចាំ ខែឧសភា ឆ្នាំ២០១៩ វេលាម៉ោង ២៣ និង៣០ នាទី ខ្លួនបានណាត់ជួបឈ្មោះ [redacted] សុខណៃ នៅមុខវត្តព្រែកលាភ សង្កាត់ព្រែកលាភ ខណ្ឌជ្រោយចង្វារ ដើម្បីទិញម៉ូតូមួយគ្រឿង ម៉ាកស៊ុយស៊ុយគីលែត ពណ៌ ខៀវស គ្មានស្លាកលេខ ពីឈ្មោះ [redacted] សុខណៃ ក្នុងតំលៃ ៧០០ (ប្រាំពីររយ) ដោយឈ្មោះ [redacted] សុខណៃ បានប្រាប់ថា ម៉ូតូនេះវាប៉ុពីគេមក ស្ថិតនៅមុំវត្តឃ្លុង ខេត្តត្បូងឃ្មុំ ។ ស៊ីសង្វាក់ជាមួយចម្លើយរបស់ឈ្មោះ [redacted] សូណាល់ និងឈ្មោះ [redacted] ករុណា បង្ហាញថា ឈ្មោះ [redacted] សម្បត្តិ ពិតជាបានទិញម៉ូតូពីឈ្មោះ ឡេង សុខណៃ ដោយដឹងថា ម៉ូតូនោះបានមកពីអំពើចោរកម្មដែរ ។

៤-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] វិចិត្រ បានឆ្លើយថា៖ ខ្លួនមិនបានចូលរួមធ្វើសកម្មភាពប្លន់ជាមួយឈ្មោះ [redacted] សូណាល់,ឈ្មោះ [redacted] សុខណៃ និងឈ្មោះ [redacted] ករុណា ទេ ហើយក៏មិនដែលស្គាល់ឈ្មោះ [redacted] សម្បត្តិ, ឈ្មោះ [redacted] ករុណា, ឈ្មោះ [redacted] សូណាល់,ឈ្មោះ ប៉ូម និងឈ្មោះ [redacted] សុខណៃ ដែរ ។ ជនជាប់ចោទគ្មានភស្តុតាងដោះបន្ទុកគ្រប់គ្រាន់ឲ្យពិចារណាបានឡើយ ។

៥-តាមចម្លើយរបស់ជនជាប់ចោទ, អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី, អំណានចម្លើយរបស់សាក្សី, កំណត់ហេតុធ្វើតេស្តស្វែងរកសារធាតុញៀន និងរបាយការណ៍ស៊ើបអង្កេត ព្រមទាំងវត្ថុតាងដែលប្រមូលបានដោយមន្ត្រីនគរបាលយុត្តិធម៌ គឺជាភស្តុតាងដាក់បន្ទុកមានលក្ខណៈគ្រប់គ្រាន់អាចពិចារណាបាន។

៦-ពិនិត្យលើសកម្មភាពរបស់ជនជាប់ចោទឈ្មោះ [redacted] សម្បត្តិ ដែលបានទទួលទិញម៉ូតូម៉ាកឡិត ដែលកើតចេញពីអំពើលួចមានស្ថានទម្ងន់ទោសដោយការប្រើប្រាស់អាវុធ និងប្រើប្រាស់នូវសារធាតុញៀន គឺជាការប្រព្រឹត្តនូវបទល្មើសទទួលផលចោរកម្ម ដែលច្បាប់បញ្ញត្តិឱ្យនិយមន័យ និងផ្តន្ទាទោសតាមមាត្រា ៣៩៩ និងមាត្រា ៤០០ នៃក្រមព្រហ្មទណ្ឌ ។ ចំពោះការចោទប្រកាន់លើជនជាប់ចោទ ពីបទ លួចមានស្ថានទម្ងន់ទោស តាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃ



Scanned with CamScanner

ក្រមព្រហ្មទណ្ឌ ពុំមានធាតុផ្សំបទល្មើសត្រឹមត្រូវនោះទេ គប្បីកែប្រែបទចោទ ។ ចំណែកឯសកម្មភាពរបស់ជនជាប់ចោទឈ្មោះ [redacted] សុខណៃ, ឈ្មោះ [redacted] សួណាល់ ហៅ សួណា, ឈ្មោះ [redacted] ករុណា ហៅ កាក់, ឈ្មោះ [redacted] សំអូន ហៅ ប៊ូម និងឈ្មោះ [redacted] វិចិត្រ ហៅ [redacted] ចិត្ត ដែលបានធ្វើសកម្មភាពដកដាវគម្រាមប្លន់យកម៉ូតូរបស់ជនរងគ្រោះ ដើម្បីយកមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន គឺជាការប្រព្រឹត្តដោយចេតនានូវបទល្មើស **លួចមានស្ថានទម្ងន់ទោស** ដែលច្បាប់បញ្ញត្តិឱ្យនិយមន័យ និងផ្តន្ទាទោសតាមមាត្រា៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។ ជនជាប់ចោទឈ្មោះ [redacted] សុខណៃ, ឈ្មោះ [redacted] សួណាល់ ហៅ សួណា, ឈ្មោះ [redacted] ករុណា ហៅ កាក់ និងឈ្មោះ [redacted] សម្បត្តិ បានប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ដែលច្បាប់បានកំណត់ហាមឃាត់ ដោយមានកំណត់ហេតុធ្វើតេស្តស្វែងរកសារធាតុញៀន របស់ការិយាល័យនគរបាលព្រហ្មទណ្ឌកំរិតស្រាលលើ បញ្ជាក់ថាលទ្ធផល **វិជ្ជមាន (មានសារធាតុញៀន)** ។

៧-ជនជាប់ចោទជានីតិជន មានសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវនូវអំពើរបស់ខ្លួនដែលបានប្រព្រឹត្ត ។

៨-អំពើរបស់ជនជាប់ចោទ ធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សង្គម ប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សុខភាព និងសតិបញ្ញាស្មារតីដល់ខ្លួនឯង និងអ្នកដទៃដែលបណ្តាលមកពីអំពើរបស់ខ្លួន ហើយត្រូវបានច្បាប់បញ្ញត្តិថាជាបទល្មើសព្រហ្មទណ្ឌ និងតម្រូវឱ្យផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

៩-មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទ៖

-ឈ្មោះ [redacted] សម្បត្តិ ហៅ ពៅ ភេទប្រុស អាយុ ២៦ឆ្នាំ ជាតិខ្មែរ ពីបទ **ទទួលផលចោរកម្ម** និង **ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចភូមិស្រែសៀម ឃុំជីរោទិ៍ទី២ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ កាលពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៣៩៩ និងមាត្រា ៤០០ នៃក្រមព្រហ្មទណ្ឌ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

-ឈ្មោះ [redacted] សុខណៃ ភេទប្រុស អាយុ២២ឆ្នាំ, ឈ្មោះ [redacted] សួណាល់ ហៅ សួណា ភេទប្រុស អាយុ១៩ឆ្នាំ, ឈ្មោះ [redacted] ករុណា ហៅ កាក់ ភេទប្រុស អាយុ២០ឆ្នាំ, ឈ្មោះ [redacted] សំអូន ហៅ ប៊ូម ភេទប្រុស អាយុ២០ឆ្នាំ ,ឈ្មោះ [redacted] វិចិត្រ ហៅ [redacted] ចិត្ត ភេទប្រុស អាយុ១៧ឆ្នាំ ពីបទ **លួចមានស្ថានទម្ងន់ទោស** និង**ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចភូមិស្រែសៀម ឃុំជីរោទិ៍ទី២ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ កាលពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

-ឈ្មោះ [redacted] សំអូន ហៅ ប៊ូម ភេទប្រុស អាយុ២០ឆ្នាំ ,ឈ្មោះ [redacted] វិចិត្រ ហៅ [redacted] ចិត្ត ភេទប្រុស អាយុ១៧ឆ្នាំ ពីបទ **លួចមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅចំណុចភូមិស្រែសៀម ឃុំជីរោទិ៍ទី២ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ កាលពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

១០-តាមសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការសុំធ្វើកា'សន្និដ្ឋានដោយស្នើសុំកែប្រែបទចោទលើជនជាប់ចោទឈ្មោះ [redacted] សម្បត្តិ ពីបទ **លួចមាន៖ស្ថានទម្ងន់ទោស** ទៅជាបទ **ទទួលផលចោរកម្ម** បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា៣៩៩, មាត្រា ៤០០ នៃក្រមព្រហ្មទណ្ឌ និងរក្សាបទចោទពីបទ **ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ។ ទី២ រក្សាបទចោទលើជនជាប់ចោទឈ្មោះ [redacted] សុខណៃ, ឈ្មោះ [redacted] សួណាល់, ឈ្មោះ [redacted] ករុណា ពីបទ **លួចមានស្ថានទម្ងន់ទោស និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** រក្សាបទចោទលើជនជាប់ចោទឈ្មោះ [redacted] សំអូន ហៅ ប៊ូម, ឈ្មោះ [redacted] វិចិត្រ ពីបទ **លួចមានស្ថានទម្ងន់ទោស** បទល្មើសដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ទុកនៅដដែល ស្នើសុំឱ្យក្រុមប្រឹក្សាធ្វើការវិនិច្ឆ័យ និងសម្រេចផ្តន្ទាទោសលើជនជាប់ចោទទាំងប្រាំមួយនាក់នេះតាមនីតិវិធីច្បាប់ គប្បីតុលាការពិចារណា និងសម្រេចតាមច្បាប់ ។

១១-លោកស្រី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សម្បត្តិ បានធ្វើសេចក្តីសន្និដ្ឋាន: ស្នើសុំសុំឱ្យកូនក្តីខ្លួនរួចផុតពីបទចោទទាក់ទងនឹងបទល្មើស លួចមានស្ថានទម្ងន់ទោស តាមមាត្រា ២៤ នៃក្រមព្រហ្មទណ្ឌ (គោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ) គប្បីតុលាការពិចារណាសម្រេច ។

១២-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សូណាល់ បានធ្វើសេចក្តីសន្និដ្ឋាន: ស្នើសំណូមពរឱ្យលោកតុលាការប្តូរបទចោទពីតបទ លួចមានស្ថានទម្ងន់ទោស មកបទ លួច តាមមាត្រា ៣០០ នៃក្រមព្រហ្មទណ្ឌ និងសុំតុលាការផ្តល់ស្ថានសម្រាលឱ្យកូនក្តីខ្លួន គប្បីតុលាការពិចារណាសម្រេច ។

១៣-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សុខណៃ, ឈ្មោះ [redacted]ករុណា, ឈ្មោះ [redacted] សម្បត្តិ, ឈ្មោះ [redacted] វិចិត្រ និងឈ្មោះ [redacted] សំអូន បានធ្វើសេចក្តីសន្និដ្ឋាន: សុំឱ្យលោកប្រធានក្រុមប្រឹក្សាកែប្រែរបស់ឈ្មោះ [redacted] ករុណា និងឈ្មោះ [redacted] សុខណៃ បទចោទពីមាត្រា ៣៥៧ មក មាត្រា ៣៥៦ វិញ និងស្នើសុំតុលាការលើកលែងចោទប្រកាន់លើកូនក្តីខ្លួនឈ្មោះ [redacted] សំអូន និងឈ្មោះ [redacted] វិចិត្រ រួចផុតពីការចោទប្រកាន់ គប្បីតុលាការពិចារណាសម្រេច ។

១៤-វត្ថុចាប់យក៖ ដាវដែកប្រវែង៥៥ សង់ទីម៉ែត្រ ចំនួន០១ (មួយ) ដើម ជាមធ្យោបាយប្រព្រឹត្តបទល្មើស គប្បីរឹបអូសតាមមាត្រា ៦២ និងមាត្រា ៦៣ នៃក្រមព្រហ្មទណ្ឌ ។

១៥-ជនជាប់ចោទឈ្មោះ [redacted] សុខណៃ, ឈ្មោះ [redacted] សូណាល់, ឈ្មោះ [redacted] ករុណា និងឈ្មោះ [redacted] វិចិត្រ និងឈ្មោះ [redacted] សម្បត្តិ បាននិយាយសម្តីចុងក្រោយថា សុំឱ្យតុលាការបន្ធូបន្ថយទោស និងលើកលែងចោទប្រកាន់ គប្បីពិចារណា ។

## វិនិច្ឆ័យសេចក្តី

១.កែប្រែបទចោទលើជនជាប់ចោទឈ្មោះ [redacted] សម្បត្តិ ពីបទ លួចមានស្ថានទម្ងន់ទោស និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន តាមមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន មកបទ ទទួលផលចោរកម្ម និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ដែលមានបញ្ញត្តិតាមមាត្រា ៣៩៩ និងមាត្រា ៤០០ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តនៅចំណុចភូមិស្រែសៀម ឃុំជីរោទិ៍ទី២ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ កាលពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៩ ។

២-ផ្តន្ទាទោសលើជនជាប់ចោទ:

ក-ឈ្មោះ [redacted] សម្បត្តិ ហៅ ពៅ ភេទប្រុស អាយុ២៦ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ០២ (ពីរ) ឆ្នាំ ។

ពីបទ ទទួលផលចោរកម្ម និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅ ភូមិស្រែសៀម ឃុំជីរោទិ៍ទី២ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ កាលពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៩ តាមមាត្រា ៣៩៩,មាត្រា ៤០០ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

ខ-ឈ្មោះ [redacted] សុខណៃ ភេទប្រុស អាយុ២២ឆ្នាំ ជាតិខ្មែរ, ឈ្មោះ [redacted] សូណាល់ ហៅ សូណា ភេទប្រុស អាយុ១៩ឆ្នាំ ជាតិខ្មែរ, ឈ្មោះ [redacted] ករុណា ហៅ កាក់ ភេទប្រុស អាយុ២០ឆ្នាំ ជនជាតិខ្មែរ, ដាក់ពន្ធនាគារម្នាក់ៗកំណត់ ០៥ (ប្រាំ) ឆ្នាំ ។

ពីបទ លួចមានស្ថានទម្ងន់ទោស និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិស្រែសៀម ឃុំជីរោទិ៍ទី២ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ កាលពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៩ តាមមាត្រា ៣៥៣, ៣៥៧ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

គ-ឈ្មោះ [redacted] សំអូន ហៅ ប៊ិម ភេទប្រុស អាយុ២០ឆ្នាំ ជាតិខ្មែរ និងឈ្មោះ [redacted] វិចិត្រ ហៅ [redacted] ចិត្ត ភេទប្រុស អាយុ២៦ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារម្នាក់ៗកំណត់ ០៥ (ប្រាំ) ឆ្នាំ ។



Scanned with CamScanner

ពីបទ លួចមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅភូមិស្រែសៀម ឃុំជីរោទិ៍ទី២ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ កាលពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៩ តាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

៣-ចេញដីកាបង្គាប់ឲ្យចាប់ខ្លួនលើឈ្មោះ [redacted] សំអួន ហៅ ប៊ូម ដើម្បីយកមកអនុវត្តទោសតាមអំណាចសាលក្រមនេះ ។

៤-វត្ថុចាប់យក៖ ដាវដែកប្រវែង៥៥ សង់ទីម៉ែត្រ ចំនួន០១ (មួយ) ដើម ត្រូវរឹបអូស ។

សាលក្រមនេះ ជំនុំជម្រះនៅថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២០ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] សម្បត្តិ, ជនជាប់ចោទឈ្មោះ [redacted] សុខណៃ, ជនជាប់ចោទឈ្មោះ [redacted] សូណាល់, ជនជាប់ចោទឈ្មោះ [redacted]ករុណា និងជនជាប់ចោទឈ្មោះ [redacted] វិចិត្រ និងកំបាំងមុខជនជាប់ចោទឈ្មោះ [redacted] សំអួន និងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុជាតិ ។

បើកផ្លូវឱ្យប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

| | |
|---|---|
| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមជំនុំជម្រះ** |
| ហត្ថលេខា និងត្រា: [redacted] | ហត្ថលេខា និងត្រា: [redacted] |

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃព្រហស្បតិ៍ ៣កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០

| | |
|---|---|
| បានឃើញ<br>ចៅក្រមជំនុំជម្រះ | ក្រឡាបញ្ជី |
| [redacted] | [redacted] |



Scanned with CamScanner